**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកំពង់ស្ពឺ**
**ស្រុកសំរោងទង**
**រដ្ឋបាលឃុំវល្លិសរ**
លេខ..............រ.ប.ក

**របាយការណ៍សង្ខេប**
**ស្តីពីវឌ្ឍនភាព និងទិសដៅ របស់រដ្ឋបាលឃុំវល្លិសរ**

## I. ស្ថានភាពទូទៅនៃរដ្ឋបាលឃុំវល្លិសរ

១.ឃុំវល្លិសរ ក្នុងចំណោមឃុំទាំង១៥ នៃស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដែលស្ថិតនៅប៉ែតឥសាននៃខេត្ត សាលាឃុំស្ថិតនៅភូមិចំបក់ ស្របតាមបណ្តោយផ្លូវជាតិលេខ៤ ចម្ងាយប្រហែល៧គីឡូម៉ែត្រ ពីទីរួមខេត្តកំពង់ស្ពឺ ដែលមានព្រំប្រទល់៖

- ខាងជើងទល់នឹងឃុំញ្ញាយ ស្រុកសំរោងទង
- ខាងកើតទល់ឃុំត្រពាំងគង និងឃុំសំរោងទង ស្រុកសំរោងទង
- ខាងត្បូងទល់ឃុំរលាំងចក ស្រុកសំរោងទង
- ខាងលិចទល់សង្កាត់សុព័រទេព និងសង្កាត់រកាធំ ក្រុងច្បារមន ។

**ឃុំវល្លិសរមាន៖**

- មានផ្ទៃដីសរុប ៖ ២.៦៣៣ហិចតា
- ចំនួនភូមិ ៖ ២៣ភូមិ
- ចំនួនគ្រួសារ ៖ ៣,៣៨២គ្រួសារ
- ចំនួនប្រជាពលរដ្ឋសរុប ៖ ១៥,២២៧នាក់ ស្រី ៧,៩៣៤នាក់
- ចំនួនប្រជាពលរដ្ឋអាយុ១៨ឆ្នាំឡើង ៖ ១០,៣១៦នាក់ ស្រី ៥,៥៤១នាក់ ដង់ស៊ីតេ៧៥០នាក់ ក្នុង១គីឡូម៉ែត្រការ៉េ
- ចំនួនប្រជាពលរដ្ឋចំណាកស្រុកក្នុង និងក្រៅប្រទេស ៖ ១៥១នាក់ ស្រី៨៧នាក់

**២.ស្ថិតិក្រុមប្រឹក្សាឃុំ និងបុគ្គលិក**

| | | |
|---|---|---|
| - សមាជិកក្រុមប្រឹក្សាឃុំវល្លិសរ | សរុប ៩នាក់ | ស្រី០២នាក់ |
| - មេឃុំ | សរុប ១នាក់ | ស្រី០នាក់ |
| - ជំទប់ទី១ | សរុប ១នាក់ | ស្រី០នាក់ |
| - ជំទប់ទី២ | សរុប ១ នាក់ | ស្រី០នាក់ |
| - ស្មៀនឃុំ | សរុប ១នាក់ | ស្រី០នាក់ |
| - បុគ្គលិកកិច្ចសន្យា | សរុប ២ នាក់ | ស្រី១នាក់ |

- មេភូមិ សរុប ២៣នាក់ ស្រី០នាក់
- អនុប្រធានភូមិ សរុប ២៣នាក់ ស្រី០៣នាក់
- សមាជិកភូមិ សរុប ២៣នាក់ ស្រី១៩នាក់

## II. វឌ្ឍនភាព និងសមិទ្ធផលការងារសម្រេចបានកន្លងមក

### ១.ការងារសម្រុះសម្រួលវដ្ឋប្បវេណី

គិតចាប់ពីខែមករា រហូតដល់ខែធ្នូ ឆ្នាំ២០២០ ឃុំបានទទួលពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ចំនួន១២៤ករណីក្នុងនោះ៖

- បានដោះស្រាយរួចជាស្ថានពរ ចំនួន ១១៩ ករណី
- សម្របសម្រួលមិនទាន់ចប់ ចំនួន ០២ ករណី
- បានបញ្ជូលទៅសាលាស្រុកសំរោងទង ចំនួន ០៣ ករណី

### ២.ការងារអភិវឌ្ឍន៍

**ក.គម្រោងអភិវឌ្ឍន៍ប្រើប្រាស់ថវិកាមូលនិធិឃុំ**

- បានជួសជុលផ្លូវគ្រួសក្រហមបានចំនួន០៣ខ្សែ ប្រវែងសរុប ៦,៨០០ គ.ម ទីតាំងភូមិចំបក់ ភូមិរកាបាញ់ និង ភូមិទួលសំណាង ប្រើប្រាស់ថវិកាមូលនិធិឃុំចំនួន ១០៦.៧៦០.០០០រៀល(មូលនិធិអភិវឌ្ឍន៍ឆ្នាំ២០១៨)
- ជួសជុលផ្លូវក្រាលគ្រួសក្រហមបានចំនួន០៥ខ្សែ ប្រវែងសរុប៥,០៣០គ.ម ទីតាំងភូមិពងទឹក ភូមិតាគាំ ភូមិត្បែស ភូមិព្រៃទួល ភូមិព្រៃកោះ ប្រើប្រាស់ថវិកាមូលនិធិឃុំ ចំនួន១២៨.៧១០.៣០០រៀល (មូលនិធិអភិវឌ្ឍន៍ឆ្នាំ២០១៩)
- បានសាងសង់ផ្លូវបេតុងអាមេ ប្រវែង៤៧៨ម៉ែត្រ ទទឹង៦ម៉ែត្រ ទីតាំងភូមិត្បែស ឃុំវល្លិសរ ប្រើប្រាស់ថវិកាមូលនិធិឃុំចំនួន ២៥៣,២២៦,២០០រៀល (មូលនិធិអភិវឌ្ឍន៍ឆ្នាំ២០២០)។

**ខ.គម្រោងហេដ្ឋារចនាសម្ព័ន្ធ ឆ្នាំ២០២០ ដល់ឆ្នាំ២០២១ ដែលគាំទ្រដោយសប្បុរសជន និងដៃគូអភិវឌ្ឍន៍ បានអនុវត្តក្នុងឃុំវល្លិសរ៖**

| ល.រ | ឈ្មោះគម្រោង | ទីតាំង | បរិមាណ | ឯកតា | តម្លៃ | ប្រភពគាំទ្រ |
|---|---|---|---|---|---|---|
| ១ | សាងសង់សាលប្រជុំរដ្ឋបាលឃុំ | សាលាឃុំ | ១ | ខ្នង | ២៨,៤៣០$ | សប្បុរសជន,ក្រុមការងារ |
| ២ | សាង់សង់ផ្លូវបេតុងអាមេ | ភូមិត្បែស | ១៦៥ | ម | ២៧,៧២០$ | សប្បុរសជន |
| ៣ | សាង់សង់ផ្លូវបេតុងអាមេ | ភូមិត្បែស | ៤០០ | ម | ៦៧.២០០$ | លោក ស្រ៊ុន ហ៉រ |
| ៤ | សាង់សង់ផ្លូវបេតុងអាមេ | ភូមិចំការរដ្ឋ | ១,២៦០ | ម | ១២៨,០០០$ | ឧកញ៉ា អ៊ឹង ឈុនទ្រី |
| ៥ | សាងសង់ទំនប់ទឹក និងទ្វារទឹក | ភូមិតាគាំ | ១ | កន្លែង | ១៧,៣០០$ | អង្គការគ្រោះមន្តរាយណ៍ |
| ៦ | សង់លូរំដោះទឹកក្នុងផ្សារចំបក់ | ភូមិចំបក់ | ១ | ខ្សែ | ៥,៣០០$ | អង្គការគ្រោះមន្តរាយណ៍ |
| ៧ | សាងសង់ផ្លូវក្រាលកៅស៊ូ | ភូមិចំបក់ | ៧៥០ | ម | | កងវិស្វយកម្ម |
| ៨ | ស្តារប្រឡាយរងប្រភេទ២ | ភូមិព្រៃទួល | ២,៧៦៦ | ម | | ក្រសួងធនធានទឹក |
| ៩ | ស្តារប្រឡាយរងប្រភេទ២ | ភូមិត្រពាំងសង្កា | ១,៥០០ | ម | | ក្រសួងធនធានទឹក |

**៣.**លទ្ធផលការងាររបស់ (គ.ក.ន.ក) ឆ្នាំ២០២០ ជំនួយសង្គមផ្សេងទៀត មានផ្តល់សម្ភារៈបង្គន់ អនាម័យ ដល់ប្រជាពលរដ្ឋក្រីក្រចំនួន៣៧គ្រួសារ ឧបត្ថម្ភស្ត្រីក្រីក្រទៅសម្រាលកូននៅមណ្ឌលសុខភាពចំនួន១៤គ្រួសារ ។

### ៤.ការងារសន្តិសុខសណ្តាប់ធ្នាប់ និងការងារភូមិឃុំមានសុវត្ថិភាព

- ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព រដ្ឋបាលឃុំ បានផ្សព្វផ្សាយអោយប្រជាពលរដ្ឋ ដើម្បី ការពារសុវត្ថិភាពភូមិដ្ឋានរបស់យើងគ្រប់ៗគ្នា ក្នុងនោះបានពង្រឹងកម្លាំងប្រជាការពារ ចំនួន២៤៦នាក់ ស្រី0នាក់ មាន គោលដៅប្រចាំការពេលយប់ ចំនួន០៣គោលដៅ (ភូមិស្លាត្រង់ចំណុចអូរក្រាំងអំបិល ១គោលដៅ, ភូមិចំការរដ្ឋ ត្រង់ចំណុចស្ពានខាងកើតភូមិ១គោលដៅ និងភូមិចំការបុស្ស ត្រង់ចំណុចអូរខ្វិត១គោលដៅ) ដោយបានសហការ ជាមួយ កម្លាំងនគរបាល ប៉ុស្តិ៍រដ្ឋបាលឃុំវល្លិសរជាប្រចាំ។

**៥. ការងារអនុវត្តមុខងារជាភ្នាក់ងារ**

**ក.ការងារអត្រានុកូលដ្ឋានក្នុងឆ្នាំ២០២១**

- បានចុះសំបុត្រកំណើត បានចំនួន ៣៨១នាក់ ស្រី១៩៨នាក់
- បានចុះសំបុត្របញ្ជាក់កំណើត បានចំនួន ៦២នាក់ ស្រី៣៣នាក់
- បានចុះសំបុត្រអាពាហ៍ពិពាហ៍ បានចំនួន៧៦គូរ
- បានចុះសំបុត្រមរណភាព បានចំនួន ៨៦នាក់ ស្រី៤២នាក់។

**ខ.ការងារចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០២១**

- ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មីចំនួន ៣៦២នាក់ ស្រី១៨៧នាក់
- ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះបោះឆ្នោតចំនួន៨៦នាក់ ស្រី៣៧នាក់
- ប្រជាពលរដ្ឋសរុបដែលមានឈ្មោះក្នុងបញ្ជីឆ្នាំ២០២១ ចំនួន ១០,១៦៣នាក់ ស្រី៥,៥២៤នាក់ ។

**គ.ការអនុវត្តមុខងារ ជាភ្នាក់ងារផ្សេងទៀត**

- បានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រក្នុងអំឡុងពេលកូវីដ-១៩ (ចាប់អនុវត្តពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០)បានចំនួន៦១១គ្រួសារ (ក្រ១ ស្មើនឹង៣៣៥គ្រួសារ និងក្រ២ ស្មើនឹង២៧៦គ្រួសារ)
- បានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ ចំនួន២១នាក់
- បានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីសម្រាលកូន ចំនួន១២នាក់
- បានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនកុមារអាយុក្រោម ២ឆ្នាំ ចំនួន០៩នាក់ ។

III . **ការងារប្រយុទ្ធប្រឆាំងជម្ងឺកូវីដ-១៩**( Covid-19 )

អនុវត្តតាមសារាចរណែនាំ បទបញ្ជារបស់រាជរដ្ឋាភិបាលកម្ពុជា សេចក្តីណែនាំ និងសេចក្តីជូនដំណឹងរបស់ក្រសួងសុខាភិបាល ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលឃុំវល្លិសរ បានដាក់ចេញនូវវិធានការបង្ការ ការពារ ទប់ស្កាត់ គ្រប់គ្រង និងប្រឆាំងការឆ្លងរីករាលដាលនៃវីរុសកូវីដ-១៩ ឆ្លើយតបបានទាន់ពេលវេលានៅតាមបណ្តាមូលដ្ឋានភូមិ សាលារៀន វត្តអារាម មូលដ្ឋានអាជីវកម្ម និងតាមរោងចក្រសហគ្រាស។

**១.ការចុះផ្សព្វផ្សាយ**

បន្ទាប់ពីទទួលបានសេចក្តីណែនាំលេខ០០៣ សណន ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ស្តីពីការផ្សព្វផ្សាយអំពីវិធានការបង្ការ ទប់ស្កាត់ ការរាតត្បាតនៃជម្ងឺកូវីដ-១៩ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងដោយបាន ការណែនាំពីឯកឧត្តមអភិបាលខេត្ត លោកអភិបាលស្រុក បានបើកកិច្ចប្រជុំផ្សព្វផ្សាយអំពីវិធានការបង្ការ ទប់ស្កាត់ ការរាតត្បាតនៃជម្ងឺកូវីដ-១៩ សម្រាប់រដ្ឋបាលឃុំវល្លិសរ បានបង្កើតក្រុមការងារដើម្បីធ្វើការចុះផ្សព្វផ្សាយ

ពីវិធានការ ការពារ ទប់ស្កាត់ និងប្រឆាំងនឹងជម្ងឺកូវីដ-១៩ជារៀងរាល់ថ្ងៃ ចាប់ពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ រហូតដល់បច្ចុប្បន្ន មានដូចខាងក្រោម៖

- ចុះផ្សព្វផ្សាយសរុបចំនួន១៦៥លើក
- ប្រើប្រាស់រថយន្តសរុបចំនួន០៧គ្រឿង (ម៉ូតូចំនួន១៥១គ្រឿង មេក្រូ៧៨គ្រឿង និងអ្នកចូលរួម ចុះផ្សព្វផ្សាយចំនួន១.២៧៣នាក់ និងបានបិទផ្ទាំងផ្សព្វផ្សាយ(Poster)ស្តីពីការកាត់បន្ថយហានិភ័យ ពីការឆ្លងជម្ងឺកូវីដ-១៩ ចំនួន២.៨១២សន្លឹក)។

## IV. ទិសដៅការងារបន្តរបស់រដ្ឋបាលឃុំវល្លិសរ សម្រាប់ឆ្នាំ២០២២

- បន្តការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋឲ្យបានទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការរបស់ ប្រជាពលរដ្ឋ ។
- ផ្សព្វផ្សាយចំណេះដឹងផ្នែកច្បាប់ ជូនប្រជាពលរដ្ឋ
- រៀបចំសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល និងអនុវត្តគម្រោងមូលនិធិឃុំប្រចាំឆ្នាំ
- បន្តការអនុវត្តហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ពីដីសគ្រួសក្រហម មកជាផ្លូវបេតុង និងផ្លូវកៅស៊ូ ។
- បន្តការជម្រុញ និងផ្សព្វផ្សាយការងារកសិកម្ម និងបន្លែគ្រប់មុខ ឲ្យបានទិន្នផលខ្ពស់ ។
- បន្តការជួសជុលប្រព័ន្ធធារាសាស្ត្រ ស្ពានប្រឡាយរងប្រភេទពីរ និងជួសជុលសំណង់ស្នក់ទឹកនៅតាមបណ្តាភូមិមួយចំនួន ។
- បន្តការផ្សព្វផ្សាយ ច្បាប់បរិស្ថាន តាមផ្លូវសាធារណៈ និងទីប្រជុំជន ។
- បន្តពង្រឹង និងផ្សព្វផ្សាយពីគោលនយោបាយ ភូមិ- ឃុំ មានសុវត្ថិភាពទាំង៧ចំណុច ដើម្បីពង្រឹងសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយ និងសុវត្ថិភាពសង្គមបានកាន់តែល្អប្រសើរដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុង ឃុំ ក៏ដូចជាការរស់នៅរបស់ប្រជាពលរដ្ឋ ។
- ខិតខំគៀងគរដៃគូ អ្នកវិនិយោគ និងសប្បុរសជនដើម្បីចូលរួមអភិវឌ្ឍន៍នៅក្នុងមូលដ្ឋាន ។
- បន្តខិតខំរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយ នៅតាមបណ្តាផ្លូវជាតិលេខ៤ និងទីសាធារណៈក្នុងភូមិសាស្ត្រឃុំ ដើម្បីរក្សាបាននូវបរិស្ថាន និងសោភ័ណភាពក្នុងឃុំ ។
- បន្តផ្សព្វផ្សាយពីវិធានការ ការពារ ទប់ស្កាត់ គ្រប់គ្រង និងប្រយុទ្ធប្រឆាំងការឆ្លងរីករាលនៃវីរុសកូវីដ-១៩ ឆ្លើយតបបានទាន់ពេលវេលានៅតាមបណ្តាមូលដ្ឋានភូមិ សាលារៀន វត្តអារាម អាជីវកម្ម រោងចក្រ សហគ្រាស ភោជនីយដ្ឋាន និងតាមកន្លែងកម្សាន្តសប្បាយនានា ទូទាំងឃុំ ។

ថ្ងៃ......................ខែ............ឆ្នាំ........ព.ស.២៥៦....

..............ថ្ងៃទី..........ខែ...........ឆ្នាំ២០២.....

**មេឃុំវល្លិសរ**